# សេចក្តីថ្លែងការណ៍របស់ដៃគូអភិវឌ្ឍន៍

## របៀបវារៈទី V: ក្របខ័ណ្ឌហិរញ្ញប្បទានប៉ាន់ស្មានពហុឆ្នាំ

**ថ្លែងដោយលោក Qimiao Fan ប្រធានធនាគារពិភពលោកប្រចាំនៅកម្ពុជា**

**តំណាងដៃគូអភិវឌ្ឍន៍នៅក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទីបី**

**រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១០**

សូមគោរព ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!

យើងខ្ញុំសូមថ្លែងអំណរគុណ ឯកឧត្តម គាត ឈន់ សម្រាប់បទបង្ហាញអំពីក្របខ័ណ្ឌហិរញ្ញប្បទានពហុឆ្នាំ ២០១០-២០១២។ ដៃគូអភិវឌ្ឍន៍នៃប្រទេសកម្ពុជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលមានឱកាស ផ្តល់ជូននូវការប៉ាន់ស្មាននៃការផ្តល់ហិរញ្ញប្បទានសម្រាប់រយៈពេលមធ្យមរបស់យើង យើងខ្ញុំនឹងផ្តល់ការគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣របស់រាជរដ្ឋាភិបាល សំដៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ទោះបីជាមានផលប៉ះពាល់បង្ករដោយវិបត្តិសេដ្ឋកិច្ចពិភពលោក និងឧបសគ្គទាំងឡាយដែលប៉ះពាល់លើថវិការបស់ដៃគូអភិវឌ្ឍន៍ក៏ដោយ តាមរយៈតារាងក្របខ័ណ្ឌហិរញ្ញប្បទានប៉ាន់ស្មានពហុឆ្នាំ បញ្ជាក់យ៉ាងច្បាស់ថា ដៃគូអភិវឌ្ឍន៍នៅតែមានការប្តេជ្ញាចិត្តគាំទ្រដល់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា យ៉ាងពេញទំហឹង ដើម្បីដោះស្រាយបាននូវបញ្ហាប្រឈមទាំងឡាយ ដែលប្រទេសកម្ពុជាជួបប្រទះ សំដៅធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌។

យើងខ្ញុំទាំងអស់គ្នានៅតែមានការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់នូវគុណភាព និងប្រសិទ្ធភាពនៃជំនួយអភិវឌ្ឍន៍ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល។ ជាពិសេស ដូចដែលយើងបានពិភាក្សាកាលពេលព្រឹកមិញនេះ យើងពិនិត្យមើលការចំណាយលើប្រាក់ឧបត្ថម្ភដល់មន្ត្រីរាជការតាមទំរង់ "ចំណាយប្រតិបត្តិការអាទិភាព" ដែលជាដំដោះស្រាយបណ្តោះអាសន្ន។ យើងខ្ញុំសង្ឃឹមយ៉ាងខ្លាំងថា ការដឹកនាំរបស់រាជរដ្ឋាភិបាលនឹងធ្វើការចាត់ចែងជំនួយឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈកំណែទំរង់រដ្ឋបាលសាធារណៈ ដែលនឹងធ្វើឱ្យទំរង់នេះលែងចាំបាច់តទៅទៀត។ ចំណែកដៃគូអភិវឌ្ឍន៍ នឹងនៅតែបន្តបន្សុីការគាំទ្ររបស់ខ្លួនទៅនឹងអាទិភាពនានានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយតំរង់ទិសឆ្ពោះទៅរកវិធីសាស្ត្រផ្អែកលើកម្មវិធី (Program-Based Approach) នៅតាមវិស័យជាច្រើន ទៅតាមលទ្ធភាព ដែលអាចធ្វើទៅបាន។ ទាំងនេះ នឹងតម្រូវឱ្យមានការកសាងសមត្ថភាពបន្ថែមទៀត និងបង្កើនតម្លាភាព និងសុចរឹតភាពនៃប្រព័ន្ធការងារក្នុងប្រទេស។ យើងខ្ញុំក៏មានជំនឿជឿជាក់ថា ការធានាបាននូវភាពព្យាករណ៍ និងតម្លាភាព នៃជំនួយរបស់យើងខ្ញុំ គឺជា សមាសធាតុមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពជំនួយ។

ក្របខ័ណ្ឌហិរញ្ញប្បទាន ប៉ាន់ស្មាន ដែលបានរៀបចំឡើង ដោយរួមបញ្ចូលទាំងហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ថ្មីនានា គឺជាជំហ៊ានមួយដ៏សំខាន់ ក្នុងការធានានូវថវិកាជាតិមួយ ដែលមានលក្ខណៈពេញលេញ។ យើងខ្ញុំសង្ឃឹមថា ក្របខ័ណ្ឌហិរញ្ញប្បទាន ប៉ាន់ស្មានពហុឆ្នាំនេះ នឹងត្រូវបានឆ្លុះបញ្ចាំងយ៉ាងពេញលេញនៅក្នុងថវិការាជរដ្ឋាភិបាល ដែលអនុម័តដោយរដ្ឋសភាជាតិ។ ជាងនេះទៅទៀត ជាការប្រសើរ ការចំណាយទាំងឡាយ ដែលទទួលហិរញ្ញប្បទានពីប្រភពក្នុងស្រុក និងពីប្រភពខាងក្រៅ គួរត្រូវបានអនុម័តដោយរដ្ឋសភាជាតិដោយមានវិភាជន៍ច្បាស់លាស់តាមបណ្តាវិស័យនីមួយៗ។ ជាការពិតណាស់ ទាំងនេះតម្រូវឱ្យដៃគូអភិវឌ្ឍន៍ ធ្វើឱ្យការគាំទ្ររបស់ខ្លួន កាន់តែអាចព្យាករណ៍បាន។ យើងខ្ញុំសូម លើកចំនុចនេះទៅពិភាក្សានៅក្នុងវាទិកាគណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្រាប់ការអនុម័តលើថវិកាឆ្នាំ២០១១។

ដូចដែលយើងខ្ញុំបានលើកឡើងនៅក្នុងបទអន្តរាគមន៍ក្នុងពិធីបើកវេទិកា យើងខ្ញុំទាំងអស់គ្នាមានវត្តមាននៅថ្ងៃនេះ ពីព្រោះយើងមានគោលដៅដូចគ្នា គឺដើម្បីធានាដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប។ ធនធាននានារបស់យើង ត្រូវបានផ្តល់ក្នុងការពង្រឹងភាពជាដៃគូ ដើម្បីគាំទ្រដល់ប្រទេសកម្ពុជា ដែលកំពុងតែជួបប្រទះនូវបញ្ហាប្រឈមនានា ដែលបានពិភាក្សាយ៉ាងស៊ីជម្រៅនៅក្នុងវេទិកាសម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទីបីនេះ។ ជាពិសេស ដូចបានលើកឡើងនៅក្នុងការពិភាក្សារបស់យើងនៅក្នុងវេទិកាសម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទីបីនេះ បញ្ហាសំខាន់ៗមួយចំនួន រួមមាន ការពង្រឹងតម្លាភាព និងគណនេយ្យភាពនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងធនធានធម្មជាតិនានា ហើយនិងការធានាបាននូវការធ្វើសមាហរណកម្មវិធីសាស្រ្តនៃការអនុវត្តដោយរាជរដ្ឋាភិបាលទាំងមូល ជាពិសេសការធ្វើសមាហរណកម្មនូវការកសាងផែនការយុទ្ធសាស្រ្ត ផែនការថវិកា និងការគ្រប់គ្រងជំនួយ ដែលត្រូវបានគាំទ្រដោយដៃគូអភិវឌ្ឍន៍ទាំងមូល។ ជាចុងក្រោយនេះ ការពិភាក្សារបស់យើងខ្ញុំបានគូសបញ្ជាក់ពីសារសំខាន់ ក្នុងការក្សាផ្តោតលើការយកចិត្តទុកដាក់ជាសំខាន់លើអ្នកទទួលផលពីការគាំទ្ររបស់យើង ចំពោះប្រជាជនកម្ពុជា ដែលជាមគ្គុទ្ទេសក៏ការងាររបស់យើង។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព!

យើងខ្ញុំនឹងខិតខំបន្តពង្រឹងភាពជាដៃគូឱ្យកាន់តែរឹងមាំថែមទៀត ដើម្បីធ្វើការងាររួមគ្នា ចាប់ពីពេលនេះរហូតដល់ចុងឆ្នាំ២០១០ និងនៅឆ្នាំ២០១១ ដូចដែលបានឯកភាពគ្នានៅក្នុងសូចនាករតាមដានត្រួតពិនិត្យរួមគ្នារបស់យើង និងផ្តោតការយកចិត្តទុកទៅលើលទ្ធផល នៅក្នុងគ្រប់កិច្ចសហប្រតិបត្តិការទាំងអស់របស់យើង ដើម្បីឈានទៅសម្រេចបាននូវអាទិភាពអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល។

សូមអរគុណ !